វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ: ០០២ប្រក/ថ្ងៃទី១៥ ខែ មករា ឆ្នាំ ២០០៣

## ប្រកាសស្តីពីការរៀបចំគណៈកម្មការសុរិយោដីស្រុកថាឡាបរិវ៉ាត់ខេត្តស្ទឹងត្រែង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ០២/នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង
- បានឃើញព្រះរាជក្រម លេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការ សុរិយោដី
- បានឃើញអនុក្រឹត្យលេខ ៣៤៧ អនក្រ.តត.ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- យោងប្រកាសលេខ០៧៧ ប្រកចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ខេត្ត-ក្រុង
- តាមសំណើររបស់គណៈកម្មការសុរិយោដីខេត្តស្ទឹងត្រែង

**សំរេច**

ប្រការ ១ :

ត្រូវបានតែងតាំង លោក សាយ ឈៀង អនុប្រធានការិយាល័យដនសក ស្រុកថាឡាបរិវ៉ាត់ ជាប្រធានគណៈកម្មការ សុរិយោដី ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ។

ប្រការ ២ :

គណៈកម្មការសុរិយោដីស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង មានបេសកកម្មអនុវត្តនូវភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ ៤៧អនក្រ. ចុះថ្ងៃទី ៣១ខែឧសភា ឆ្នាំ ២០០២ ស្តីពីការ រៀបចំនិងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

ប្រការ ៣:

នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីខេត្ត ស្ទឹងត្រែងប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត អស់លោកដូចមានរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

Downloaded from http://www.khmerlaws.com